# ជោរជន់ដោយសេចក្តីស្រឡាញ់

ដោយ អាឡេលី ក្លូណេល កាមីតាន់
( ផ្អែកទៅលើដំណើររឿងពិត )



*ដំណើររឿងនេះបានកើតឡើងនៅប្រទេសហ្វីលីពីន ។*

**នៅ**ពេលដែល ម៉ារីយូស ដើរទៅផ្ទះរបស់គាត់ គាត់អាចស្តាប់ឮមនុស្សនិយាយគ្នានៅខាងក្នុង ។ គាត់បានមើលតាមមាត់បង្អួច ។

*គាត់បានគិតថា* តើនរណានៅទីនេះ ។ ម្តាយរបស់គាត់ធ្វើការនៅប្រទេសក្រៅ ដូច្នេះជាទូទៅវាមានតែគាត់ និង លោកយាយឡូឡា ( ដែលជាជីដូន ) នៅផ្ទះ ។

គាត់បានបើកទ្វារ ។ មិត្តភក្តិរបស់គាត់ទាំងអស់នៅទីនោះ !

គាត់បាននិយាយថា « ភ្ញាក់ផ្អើលណាស់ ! »

ហូសេ ដែលជាមិត្តល្អបំផុតរបស់ ម៉ារីយូស បាននិយាយថា « ពួកយើងមកអបអរដល់ឯង និងមេដាយដែលឯងទទួលបានក្នុងការប្រកួតកីឡាតែក្វាន់ដូរបស់ឯងនោះ » ។

« ខ្ញុំមានមោទនភាពចំពោះឯងណាស់ » ។ លោកយាយឡូឡា ឱបរឹត ម៉ារីយូស យ៉ាងខ្លាំង ។ « ម្តាយរបស់ឯងចាំជួបតាមទូរសព្ទ ! យាយជឿជាក់ថាម៉ាក់ចៅនឹងចង់ស្តាប់អំពីរឿងមេដាយរបស់ចៅ » ។

បន្ទាប់ពី ម៉ារីយូស បាននិយាយជាមួយម៉ាក់របស់គាត់ចប់ គាត់ និងមិត្តភក្តិសប្បាយរីករាយនឹងពិធីជប់លៀង ។ ពួកគេសប្បាយរីករាយនឹងការនិយាយគ្នាលេង និង ហូបម្ហូបដ៏ឆ្ងាញ់របស់ លោកយាយឡូឡាធ្វើ ។

« ចង់ទៅបោះបូលីង ជាមួយខ្ញុំនៅថ្ងៃស្អែកទេ ? » ហូសេ បានសួរពីមុនគាត់ចេញទៅ ។

« បាទ ! » ម៉ារីយូស បាននិយាយ ។

មុនចូលគេងនៅយប់នោះ ម៉ារីយូស បានពោលពាក្យអធិស្ឋាន ។ « ព្រះវរបិតាសួគ៌ សូមអរព្រះគុណដែលប្រទានមិត្តភក្តិ និងគ្រួសារដ៏ល្អៗបែបនោះ ។ សូមប្រទានពរដល់ម្តាយរបស់ខ្ញុំកាលដែលគាត់នៅឆ្ងាយពីផ្ទះ ។ ហើយសូមជួយទូលបង្គំបានសប្បាយរីករាយនៅពេលទៅលេងបោះបូលីងនៅថ្ងៃស្អែកជាមួយ ហូសេ » ។

ប៉ុន្តែនៅថ្ងៃស្អែកនោះ ម៉ារីយូស ពុំបានទៅលេងបោះបូលីងនោះទេ ។ មានព្យុះដ៏ធំមួយបានកើតឡើង ហើយមនុស្សទាំងអស់ត្រូវនៅក្នុងផ្ទះ ។ ម៉ារីយូស អង្គុយនៅក្នុងផ្ទះ ស្តាប់សំឡេងទឹកភ្លៀងស្រក់ពីលើដំបូលផ្ទះ ។ គាត់ចង់ជួបនឹង ហូសេ ណាស់ ។

ភ្លៀងបន្តធ្លាក់អស់រយៈពេលបីថ្ងៃហើយ ។ ទឹកជំនន់ជោរជន់ពេញលើផ្លូវ ។ ផ្ទះមួយចំនួននៅជិតខាងរបស់ម៉ារីយូស ក៏បានជន់លិចដែរ ។

ក្រោយមក ម៉ារីយូស បានឃើញ លោកយាយឡូឡា នៅផ្ទះបាយ ។ គាត់កំពុងធ្វើម្ហូបដែលមានក្លិនដ៏ឈ្ងុយឆ្ងាញ់ ។

គាត់បានសួរថា « តើលោកយាយកំពុងធ្វើអ្វីហ្នឹង ? »

គាត់បានឆ្លើយថា « យាយកំពុងធ្វើម្ហូបឲ្យក្រុមគ្រួសារខ្លះនៅក្នុងវួដរបស់យើង » ។ « ផ្ទះរបស់ពួកគេលិចទឹកអស់ហើយ អីចឹងហើយ ប៊ីស្សពបានសុំឲ្យយាយជួយ » ។

ម៉ារីយូស បានគិតអំពី ហូសេ ។ « តើយើងអាចធ្វើម្ហូបឲ្យគ្រួសារ ហូសេ ផងបានទេលោកយាយ ? ពួកគាត់ក៏ប្រហែលជាត្រូវការម្ហូបផងដែរ » ។

លោកយាយឡូឡាបានតបថា « នោះជាគំនិតល្អណាស់ » ។

ម៉ារីយូស បានធ្វើបាយ និងចៀនពងទាឲ្យគ្រួសារ ហូសេ ។ បន្ទាប់មក គាត់បានជួយលោកយាយឡូឡា វេចខ្ចប់ម្ហូបនោះ ។

នៅទីបំផុត ភ្លៀងក៏បានឈប់ ។ ម៉ារីយូស និង លោកយាយឡូឡា បានដើរទៅផ្លូវដើម្បីចែកអាហារ ។ ទឹកលិចដល់ជង្គង់របស់ ម៉ារីយូស !

ពួកគេបានឃើញ ហូសេ និងគ្រួសាររបស់គាត់កំពុងឈរនៅក្រៅផ្ទះរបស់ពួកគេ ។ ហូសេ កំពុងយំ ។

ម៉ារីយូស បានឱបមិត្តរបស់គាត់ ។ គាត់បាននិយាយថា « ខ្ញុំសោកស្តាយណាស់ដែលផ្ទះរបស់ឯងត្រូវលិចទឹក » ។ « ព្រះយេស៊ូវស្រឡាញ់ឯង ។ ហើយពួកយើងក៏ស្រឡាញ់ឯងដែរ » ។

ទាំងម៉ារីយូស និងហូសេ បានជួយសម្អាតរបស់កខ្វក់នៅក្នុងផ្ទះរបស់ហូសេ ។ ម៉ារីយូស បានច្រៀងបទ « ខ្ញុំជាកូនរបស់ព្រះ » កាលដែលពួកគេបានធ្វើការ ។ នៅពេលពួកគេសម្រាក ម៉ារីយូស បានឲ្យអាហារដែលគាត់ធ្វើទៅហូសេ ។

ហូសេ បាននិយាយថា « អរគុណដែលបានជួយគ្រួសារខ្ញុំ » ។ « ហើយអរគុណសម្រាប់អាហារនេះ ! វាឆ្ងាញ់ណាស់ » ។

ម៉ារីយូស បាននិយាយថា « មិនអីទេ » ។

ហូសេ បានសួរថា « តើឯងគិតថា ឯងអាចប្រាប់ខ្ញុំបន្ថែមអំពីព្រះយេស៊ូវបានទេ ? និងបទចម្រៀងដែលឯងបានច្រៀងនោះ ? »

« ប្រាកដជាបាន ! » ម៉ារីយូស បាននិយាយ ។ « តើឯងចង់ទៅព្រះវិហារជាមួយខ្ញុំនៅថ្ងៃអាទិត្យនេះទេ ? នោះជាកន្លែងដែលខ្ញុំរៀនអំពីព្រះយេស៊ូវ ។ ហើយយើងក៏អាចច្រៀងជាមួយគ្នាដែរ » ។

ហូសេ បានឆ្លើយថា « យល់ព្រម » ។

ម៉ារីយូស មានអារម្មណ៍កក់ក្តៅនៅក្នុងចិត្ត ។ គាត់ត្រេកអរណាស់ដែលគាត់អាចជួយ ហូសេ និងគ្រួសាររបស់គាត់ ។ ហើយគាត់សប្បាយចិត្តដែលគាត់អាចចែកចាយដំណឹងល្អផងដែរ ។ ●



